សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ អត្ថន័យរបស់ពាក្យលោភៈ

www.hoksavann.org

ថ្ងៃទី២១ មេសា ២០១៣



ពាក្យថា លោភចិត្ត ឬចិត្តលោភ ចេញមកពីបាលីថា ***លោភោ*** ប្រែថា សភាពធ្វើចិត្តឲ្យជាប់ជំពាក់នៅក្នុងអារម្មណ៍ ។ លោភចិត្តនេះ ជាអកុសលមូលមួយក្នុងចំណោមអកុសល អកុសលមូលទាំងបីគឺ ***លោភៈ ទោសៈ*** និង ***មោហៈ*** ។ អកុសលមូលទាំងបីនេះជាឫសគល់នៃអកុសលទាំងពួង ។ រួចមកហើយមានអ្នកខ្លះយល់ច្រឡំថា បើព្រះពុទ្ធហាមមិនឲ្យមនុស្សលោភនឹងធ្វើឲ្យបង្អាក់ដំណើរនៃការលូតលាស់នៃសេដ្ឋកិច្ចជាតិ ។ ការយល់បែបនេះមកអំពីគេពុំយល់ពាក្យថា ***លោភៈ*** នេះឯង ។ ប្រហែលជាគេយល់ថា កុំឲ្យលោភបានន័យថា កុំឲ្យចង់បានច្រើន ពុំមែនមានន័យដូច្នេះឡើយ ។ មិនឲ្យលោភពុំមែនបានសេចក្ដីថាហាមមិនឲ្យរៀនសូត្រ មិនឲ្យរកស៊ីធ្វើការចិញ្ចឹមជីវិតឡើយ សូម្បីព្រះសង្ឃព្រះពុទ្ធសាសនា ដែលលះបង់អ្វីទាំងអស់ ហើយមកបួសក៏លោកស្វែងរកបច្ច័យ៤ ដើម្បីចិញ្ចឹមជីវិតប្រព្រឹត្តទៅជាធម្មតា ។ ព្រះពុទ្ធមិនត្រឹមតែពុំហាមទេ ថែមទាំងដាស់តឿនឲ្យខំប្រឹងប្រែងថែមទៀត ដូចជាពាក្យថា ***ឧបដ្ឋានសម្បទា*** ប្រែថា ការខំប្រឹងប្រែងរៀនសូត្រធ្វើការងារចិញ្ចឹមជីវិតឲ្យបានខ្លាំងក្លា តែត្រូវជៀសវាងការងារមិនប្រកបដោយធម៌ គឺការងារទុច្ចរិតនិងអយុត្តិធម៌ ។ ***អារក្ខសម្បទា*** មានចំណេះវិជ្ជាហើយ បានទ្រព្យសម្បត្តិហើយ ត្រូវរក្សាឲ្យគង់វង្សជាដើម ។ ធម៌នេះមាននិយាយក្នុងប្រយោជន៍បច្ចុប្បន្ន៤យ៉ាង ។

ធម៌ដែលព្រះពុទ្ធមិនឲ្យលោភនេះ មានន័យយ៉ាងជ្រាលជ្រៅណាស់ ដែលជារូបមន្តរម្ងាប់សេចក្ដីទុក្ខផ្លូវចិត្តរបស់មនុស្ស ។ មានវិគ្គហៈថា ***លុព្ភតីតិ លោភោ*** កន្លែងខ្លះប្រែថាចង់បាន កន្លែងខ្លះប្រែថាការជាប់ចិត្ត ។ របស់អ្វីទាំងអស់ ទាំងមានវិញ្ញាណ ទាំងឥតវិញ្ញាណ តែងតែស្ថិតនៅក្នុងភាពពុំទៀង តែងតែផ្លាស់ប្ដូរប្រែប្រួល ហើយទីបំផុតត្រូវវិនាសត្រូវស្លាប់ទៅវិញ ។ បើចិត្តមនុស្សនៅតែជាប់ (លោភៈ) នូវរបស់ដែលវិនាសហើយនោះ គេនឹងកើតទុក្ខផ្លូវចិត្តចំពោះសត្វ (របស់មានវិញ្ញាណ) និងសង្ខារ (របស់ឥតវិញ្ញាណ) ដែលវិនាសបាត់បង់ទៅហើយនោះ ។ ក្នុងទុក្ខ១២កង មានទុក្ខមួយកងពោលថា សេចក្ដីទុក្ខកើតអំពីការបាត់បង់របស់ជាទីស្រឡាញ់របស់ខ្លួន (***បិយេហិ វិប្បយោគោ ទុក្ខោ***) ។ ដូច្នេះបើចិត្តមិនជាប់ (អលោភៈ) សេចក្ដីទុក្ខផ្លូវចិត្តក៏ពុំមានដែរ ។ ព្រះពុទ្ធសាសនាសំដែងឲ្យពិចារណា សង្ខារទាំងឡាយកើតមកហើយ តែងស្លាប់បាត់បង់ទៅវិញ មនុស្សសត្វទាំងឡាយតែងតែព្រាត់ប្រាស់គ្នាជាធម្មតា ដូច្នេះការសោកស្ដាយយំសោក ពុំអាចរស់ឡើងវិញឡើយ នាំតែខូចផ្លូវចិត្តប៉ុណ្ណោះ គួរតាំងចិត្តជាឧបេក្ខា ពិចារណាកម្មផលរបស់មនុស្សសត្វ ។ បើមានធម៌ករុណាការអាណិតអាសូរចំពោះសត្វនិងសង្ខារ ដែលស្លាប់បាត់បង់ទៅ ដែលពុំអាចរស់ឡើងវិញបាននោះ សេចក្ដីសោកស្ដាយតែងស្ថិតនៅជាប់ក្នុងចិត្ត មានខ្លះសោកស្ដាយខ្លាំងរហូតធ្វើអត្តឃាតសម្លាប់ខ្លួនឯងក៏មាន ។ ការសោយសោកនេះ មកអំពីចិត្តជាប់ (លោភៈ) មិនពិចារណាឃើញការពិត ហើយលះបង់ចិត្តជាប់នេះ ។ បានសេចក្ដីថា បើម្ដាយឪពុក ជីដូនជីតា បងប្អូន កូនចៅនៅរស់ ត្រូវតែគោរពគ្នា សង្គ្រោះគ្នា ស្រឡាញ់រាប់អានគ្នា ដល់ពេលស្លាប់ ជាការបាត់បង់ព្រាត់ប្រាស់គ្នា ត្រូវប្រើទឹកចិត្តមួយផ្សេងពីនេះ ដោយពិចារណាកម្មផលរបស់មនុស្សសត្វប្រកបដោយឧបេក្ខាចិត្ត បើចិត្តផ្លាស់ប្ដូរមិនទាន់ចិត្តរមែងកើតទុក្ខ ។ ចិត្តរបស់មនុស្សបុថុជ្ជនផ្សេងពីចិត្តរបស់ព្រះអរិយបុគ្គល ដែលជាព្រះអរហន្តមានញាណទស្សនៈឃើញការពិតថា រូបរាងកាយរបស់មនុស្ស ដែលប្រកបដោយខន្ធប្រាំគឺ ***រូប វេទនា សញ្ញា សង្ខារ*** និង ***វិញ្ញាណ*** ពុំមែនជាសត្វ ជាបុគ្គល មានសភាពសោះសូន្យទទេ ។ បានសេចក្ដីថា ***ខន្ធ៥*** គ្រាន់តែជាធាតុកើតឡើង តាំងនៅ និងរលត់ទៅវិញជាធម្មតា ជា***អនត្តា*** មិនមែនខ្លួនជាសភាវធម៌ប្រព្រឹត្តទៅដោយខ្លួនវា ពុំអាចបង្គាប់បញ្ជាបានឡើយ ដូច្នេះហើយបានជាព្រះអរហន្តមាន ***ព្រះពុទ្ធ*** ជាដើម លោកពុំតក់ស្លុតភ័យខ្លាច សោកស្ដាយនូវជីវិត ទោះបីដល់នៅសេចក្ដីស្លាប់ក៏ដោយ ។ លោកបាត់ទុករូបរាងកាយជាធាតុ៤ ដូចធាតុខាងក្រៅ បានជាមិនភ័យតក់ស្លុត ព្រោះលោកមិនជាប់ (***អលោភៈ***) ។ លោកនៅថែទាំរូបរាងកាយ និងប្រើប្រាស់បច្ច័យ៤ មានចីវរបច្ច័យជាដើម ប៉ុន្តែបើរូបរាងកាយនិងវត្ថុទាំងនោះវិនាស ក៏លោកមានព្រះទ័យស្មើ មិនតក់ស្លុតមិនសោកស្ដាយសោះឡើយ ។ ***លោភៈ*** ការចង់បាន ឬការជាប់ជំពាក់ខ្លាំង អាចជំរុញចិត្តឲ្យលួចទ្រព្យសម្បត្តិអ្នកដទៃ និងជម្រុញឲ្យធ្វើឃាតកម្មអ្នកដទៃ ដើម្បីបានទ្រព្យសម្បត្តិដូចជាចោរប្លន់ សម្លាប់អ្នកម្ចាស់ទ្រព្យ ឬចាប់ជំរិតមានទារប្រាក់ជាដើម ។ បើអ្នករដ្ឋការវិញ ប្រព្រឹត្តអំពើពុករលួយដោយការលោភហួសព្រំដែន បាលីថា ***អភិជ្ឈាវិសមលោភ*** ប្រែថា ការសម្លឹងរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃ និងទ្រព្យសម្បត្តិជាតិ ។ ធម៌អកុសល គឺលោភៈនេះហើយដែលធ្វើឲ្យប្រទេសក្នុងពិភពលោកមានចោរលួច ចោរប្លន់ លួចរំកិលព្រំដែន កើតការវិវាទរវាងប្រទេសជិតខាងគ្នា ដូចប្រទេសកម្ពុជាដែលកំពុងមានបញ្ហាទឹកដីជាមួយប្រទេសជិតខាងទាំង៣ជាដើម ។ ការរំលោភសិទ្ធិប្រជាពលរដ្ឋរបស់អ្នកកាន់អំណាច ក៏មកពីការលោភលន់ហួសប្រមាណនេះឯង ។ សង្គ្រាមសកលលោកទាំងពីរលើកក៏បណ្ដាលមកពីមហិច្ឆិតាលោភលន់ ចង់ត្រួតត្រាលើសកលលោកដាច់មុខតែម្នាក់ឯង ។ ***លោភៈ*** គ្រប់សង្កត់បិទបាំងមិនឲ្យបុគ្គលនឹកឃើញភាពពុំទៀង (***អនិច្ចំ***) នៃរូបរាងកាយឡើយ ។ គម្ពីរព្រះពុទ្ធសាសនាសំដែងថា កាលណាសន្តានចិត្តនៃមនុស្សក្រាស់ដោយលោភៈ រមែងកើត ***ទុរ្ភិក្ស*** និងអន្តរាយផ្សេងៗដល់មនុស្សក្នុងបច្ចុប្បន្ន ហើយមនុស្សសត្វដែលទៅកើតជាប្រេតក៏មកអំពី ***លោភមូលចិត្ត*** នេះដែរ ។

*ដូចពោលមកហើយ ព្រះពុទ្ធបានសំដែងក្នុងធម៌អភិធម្មអំពីលោភចិត្តនេះថា ជាឫសគល់នៃអកុសលទាំងឡាយ នាំសត្វឲ្យមានទុក្ខ ។ បើមាន «**អលោភចិត្ត**» គឺចិត្តមិនលោភ ជាឫសគល់នៃកុសលទាំងឡាយ នាំឲ្យសត្វបានសុខ ។ កាលណាចិត្តមិនលោភ បានន័យថាមិនជាប់ ទោះបីរបស់នោះវិនាសទៅក៏មិនកើតទុក្ខ ព្រោះរបស់អ្វីទាំងអស់ដែលកើតឡើងពីគ្រឿងផ្សំ តែងតែវិនាសទៅវិញជាធម្មតា ។ **អានិសង្ស** នៃការមិនលោភ នាំឲ្យមនុស្សប្រកបកិច្ចការងារគ្រប់យ៉ាងប្រកបដោយធម៌ **(សម្មាអាជីវោ)** មិនត្រឹមតែធ្វើខ្លួនអ្នកប្រព្រឹត្តឲ្យបានសុខទេ ថែមទាំងធ្វើឲ្យសង្គមបានសុខផង ព្រោះពុំមានធម៌ **អទិន្នាទាន** ការលួចប្លន់ ។ ការមិនលោភមិនត្រឹមតែពុំបង្អាក់ដំណើរការលូតលាស់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិទេ ថែមទាំងធ្វើឲ្យសេដ្ឋកិច្ចទាំងពីរនេះលូតលាស់ថែមទៀត ព្រោះមនុស្សដែលមានចិត្តមិនលោភ ជាមនុស្សមានចិត្តខ្ពស់ មានបញ្ញាជ្រៅជ្រះជ្រៅ ខំប្រឹងប្រែងធ្វើជីវិតខ្លួន និងជីវិតសង្គមឲ្យចំរើនលូតលាស់ខាងសម្ភារៈ និងសីលធម៌ប្រកបដោយធម៌ ហើយរបស់ណាដែលបានមក ឬកើតឡើងដោយធម៌ របស់នោះទុកគង់វង់ស្ថិតស្ថេរ ។*

* *

*